# Living the Lotus 9

## Buddhism in Everyday Life

2026
VOL. 252




## Rissho Kosei-kai of Taipei Holds Memorial Services for Ancestors on August 25 Following a Two-Day Devotional Recitation of the Threefold Lotus Sutra

**Living the Lotus**
**Vol. 252 (September 2026)**

Senior Editor: Takashi Maeda
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីស្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។
អង្គការរីស្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីស្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# សូមឱ្យយើងម្នាក់ៗអុជចង្កៀងមួយ

ដោយព្រះគ្រូនីវ៉ាណូ នីជីកុ
ព្រះប្រធានរីស្សូកូសេកៃ




## ជាជាងត្អូញត្អែរអំពីភាពងងឹត

រហូតមកដល់ពេលនេះក៏ដោយក៏មនុស្សជាច្រើននៅជុំវិញពិភពលោកកំពុងតែរងទុក្ខវេទនាដោយសារសង្គ្រាមនិងការគាបសង្កត់។ ចាប់តាំងពីរដូវផ្ការីកកន្លងទៅនេះសម្តេចប៉ាបឡេអូទី១៤នៃព្រះវិហារកាតូលិក បានអំពាវនាវដល់មេដឹកនាំនៃប្រទេសនានាក្នុងពិភពលោកឱ្យ «ខិតខំបញ្ចប់សង្គ្រាមនិងលើកកម្ពស់សន្តិភាពព្រមទាំងការផ្សះផ្សា» ដោយសង្កត់ធ្ងន់លើតម្រូវការ «បញ្ឈប់ការគោរពបូជាខ្លួនឯងនិងគោរពប្រាក់កាសព្រមទាំងបញ្ឈប់ការបង្ហាញអំណាចពីព្រោះថាភាពខ្លាំងពិតប្រាកដគឺត្រូវបង្ហាញតាមរយៈការបម្រើនិងឱ្យតម្លៃដល់ជីវិត»។

ក៏ប៉ុន្តែមានព្រឹត្តិការណ៍ដ៏គួរឱ្យភ្ញាក់ផ្អើលមួយដែលមិនធ្លាប់មានពីមុនមកគឺមានមេដឹកនាំប្រទេសមួយរូបបានធ្វើការទិតៀនទៅលើសារបែបនេះរបស់សម្តេចប៉ាប។ ពិតជាគួរឱ្យសោកស្តាយយ៉ាងខ្លាំងដែលអំណោយដ៏មានតម្លៃដែលត្រូវបានប្រទានដល់មនុស្សជាតិ គឺចិត្ត និងសមត្ថភាពក្នុងការប្រើប្រាស់ភាសាត្រូវបានគេយកមកប្រើដើម្បីបង្កឱ្យមានជម្លោះនិងការបែកបាក់គ្នា។យើងមានអារម្មណ៍សោកសៅចំពោះស្ថានភាពនេះជាខ្លាំងតែមិនអាចធ្វើអ្វីបានក្រៅពីត្អូញត្អែរនិងឈរមើលនោះទេ។

ក៏ប៉ុន្តែទោះជានៅក្នុងពិភពលោកដែលហាក់ដូចជាគ្របដណ្តប់ទៅដោយភាពងងឹតនិងអនាគតដ៏មិនច្បាស់លាស់ក៏ដោយ ក៏នៅមានសារដ៏មានអានុភាពមួយដែលបញ្ជាក់ថាយើងម្នាក់ៗអាចធ្វើអ្វីមួយបាន។ គឺសារពីព្រះគ្រូយ៉ាស៊ីអ៊ូកា ម៉ាសាហ៊ីរ៉ូដែលជាទស្សនវិទូដ៏ល្បីល្បាញម្នាក់ខាង ទស្សនវិជ្ជាបូព៌ាដែលមានចំណងជើងថា "ប្រតិ បត្តិការអុជចង្កៀងមួយដើម្បីបំភ្លឺជ្រុងមួយ —ប្រតិបត្តិការអុជចង្កៀងរាប់ម៉ឺនដើម្បីបំភ្លឺគ្រប់ទីកន្លែង"។

"ជាជាងការត្អូញត្អែរអំពីភាពងងឹត ចូរយើងអុជចង្កៀងមួយ។ចូរយើងធ្វើជាចង្កៀងដែលបំភ្លឺភាពងងឹតជុំវិញខ្លួនយើងជាមុនសិន។ចូរយើងបំភ្លឺកន្លែងងងឹតមួយជ្រុងតូចមួយទោះបីជាពន្លឺនោះតូចភ្លឹបភ្លែតៗក៏ដោយ។ ចូរយើងបន្តភ្ជាប់ពន្លឺមួយនោះទៅគ្រប់ទីកន្លែងដែលដៃរបស់យើងអាចឈោងទៅដល់។ ប្រសិនបើមនុស្សម្នាក់ៗអុជចង្កៀងមួយនោះមនុស្សមួយម៉ឺននាក់នឹងអុជចង្កៀងមួយម៉ឺនហើយប្រទេសជប៉ុននឹងភ្លឺព្រោងព្រាយឡើងភ្លាមៗ។ នេះគឺជាកកិច្ចប្រតិបត្តិរបស់យើងដោយអុជចង្កៀងមួយដើម្បីបំភ្លឺជ្រុងងងឹតមួយ ហើយតាមរយៈទង្វើនោះ ការបំភ្លឺដោយចង្កៀងរាប់មិនអស់នៅគ្រប់ទីកន្លែងនឹងមានឡើង។ចូរយើងប្រឹងប្រែងយ៉ាងមោះមុតក្នុងបេសកកម្មកែលំអពិភពលោកនេះ។"

ពាក់ព័ន្ធនឹងពាក្យថា "ប្រទេសជប៉ុន" នៅក្នុងសារប្តេជ្ញាចិត្តដែលបានលើកឡើងមកនេះ ប្រហែលជាគួរតែប្រើពាក្យថា "ពិភពលោក" វិញទើបសមជាង។ លើសពីនេះទៅទៀត ខ្ញុំព្រះករុណាអាត្មាភាពយល់ថាពាក្យថា "បេសកកម្មកែលំអពិភពលោក" មិនមែនជាការអំពាវនាវឱ្យបុគ្គលណាម្នាក់ធ្វើការផ្លាស់ប្តូរដ៏ធំធេងតែម្នាក់ឯងនោះ

ទេ ប៉ុន្តែវាជាការអំពាវនាវឱ្យមានសកម្មភាពជាក់ស្តែងដែលយើងម្នាក់ៗអាចធ្វើបានដោយមិនលះ បង់ខ្លួនឯងដើម្បីកែលំអអ្វីៗដែលនៅជិតខ្លួនយើង—ដែលជាការបន្តពីគំនិតដែលខ្ញុំព្រះករុណាអាត្មាភាពបានចែករំលែកកាលពីខែមុនថា៖ "ប្រសិនបើអ្នកអុជចន្លុះដើម្បីបំភ្លឺផ្លូវឱ្យអ្នកដទៃ..."

សម្តេចប៉ាបបានមានបន្ទូលថា "ទោះបីជាមានជំនឿទៅលើសាសនាត្រឹមតែបន្តិចបន្តួចក៏ដោយក្នុងនាមជាមនុស្សជាតិនិងដោយសហការគ្នាក៏យើងអាចប្រឈមមុខនឹងសម័យកាលដ៏ច្របូកច្របល់នៃប្រវត្តិសាស្ត្រនេះបានដែរ"។ នៅពេលដែលសកម្មភាពប្រចាំថ្ងៃរបស់បុគ្គលម្នាក់ៗក្លាយជាពន្លឺដែលបំភ្លឺជ្រុងមួយនៃពិភពលោក ហើយនៅពេលដែលពន្លឺទាំងនោះកើនឡើងដល់រាប់រយលាន ឬរាប់ពាន់លាននោះយើងអាចរំពឹងទុកនូវអនាគតដ៏ភ្លឺស្វាងសម្រាប់ភពផែនដីរបស់យើង—ជាអនាគតដ៏សក្តិសមសម្រាប់ផ្កាយមួយដួងដែលបញ្ចេញពន្លឺពណ៌ខៀវវិចិត្រនៅក្នុងលំហអាកាសដ៏ងងឹតសូន្យសុង។

## ក្នុងកម្រិតដែលយើងអាចឈោងដៃទៅដល់

នៅក្នុងសារនេះមានឃ្លាមួយចែងថា «ចូរយើងបង្កើនពន្លឺនៅគ្រប់ទីកន្លែងដែលយើងអាចឈោងដៃទៅដល់» អាចបកស្រាយបានថា «នៅក្នុងដែនកំណត់នៃអ្វីដែលយើងអាចធ្វើបានដោយមិនលះបង់ខ្លួនឯង»។ ឃ្លានេះបង្រៀនយើងថាសកម្មភាពនៃការផ្តល់ឬការធ្វើទាន—ដែលមិនបង្កជាបន្ទុកធ្ងន់ធ្ងរពេកដល់ខ្លួនយើង—អាចក្លាយជាពន្លឺដែលអាចបំភ្លឺពិភពលោកដ៏ងងឹតបាន។ នៅពេលដែលពិចារណាលើចំណុចនេះ វាហាក់ដូចជាមិនមែនជារឿងចៃដន្យឡើយ ដែលថ្ងៃទី ១០ ខែកញ្ញានេះ គឺជាថ្ងៃប្រារព្ធពិធី *ហូអុងកៃ (ពិធីថ្លែងអំណរគុណ) ដល់ *វ៉ាគីសូសាម៉ា * (ព្រះនាមដើមលោកស្រីណាង៉ានុម៉ា មីយោកុដែលជាសហស្ថាបនិកនៃអង្គការរបស់យើង)។

វ៉ាគីសូសាម៉ាជាបុគ្គលដែលចាត់ទុកមនុស្សគ្រប់រូបដែលគាត់បានជួបថាជាកូនបង្កើតរបស់ខ្លួនឯង ហើយគាត់តែងតែផ្តល់ការណែនាំដែលពេលខ្លះមានភាពម៉ឺងម៉ាត់ ក៏ប៉ុន្តែពោរពេញដោយភាពកក់ក្តៅ។ គាត់បានលះបង់ខ្លួនឯងក្នុងសកម្មភាពមេត្តាធម៌ដែលពិតជាឆ្លុះបញ្ចាំងពីស្មារតីនៃ «ការបង្កើនពន្លឺចង្កៀងនៅគ្រប់ទីកន្លែងដែលយើងអាចឈោងដៃទៅដល់»។ រាល់ពេលដែលគាត់បានជួបអ្នកដែលត្រូវការជំនួយ គាត់តែងតែផ្តល់អ្វីៗដែលគាត់មានដោយមិនស្ទាក់ ស្ទើរឡើយ មិនថាជាអាហារ ឬសម្ភារៈ (ដូចជាភួយឬខ្នើយ) ប្រាក់កាស ឬសូម្បីតែសម្លៀកបំពាក់ដែលគាត់កំពុងតែស្លៀកពាក់ជាប់នឹងខ្លួនក៏ដោយ។ គាត់ចាត់ទុកអ្វីៗទាំងអស់ថាជាវត្ថុដែល «ព្រះពុទ្ធបានប្រគល់មកឱ្យគាត់ដើម្បីធ្វើទានដល់អ្នកដែលមានការខ្វះខាត» ហើយគាត់នៅតែបន្តអុជចង្កៀងមួយឱ្យឆេះបំភ្លឺជានិច្ច។

នៅពេលដែលយើងងាកមកមើលជីវិតប្រចាំថ្ងៃ កម្រិតដែលយើងអាចឈោងដៃទៅដល់ គឺអ្នកដែលនៅជិតខ្លួនយើងមិនត្រឹមតែក្រុមគ្រួសារយើងតែប៉ុណ្ណោះទេ ប៉ុន្តែមានអ្នកជិតខាង អ្នកដែលអង្គុយជាប់យើងនៅលើរថភ្លើង ឬរថយន្តក្រុងនិងអ្នកដែលឈរតម្រង់ជួរជាមួយយើងនៅហាងលក់ទំនិញផងដែរ។ ការផ្តល់ស្នាមញញឹមឬពាក្យសម្តីដែលសម្តែងការដឹងគុណដល់មនុស្សទាំងឡាយនោះឬការឈោងដៃទៅជួយអ្នកដែលកំពុងជួបការលំបាក គឺប្រៀបដូចជាពន្លឺដែលបំភ្លឺបរិយាកាសជុំវិញខ្លួនយើង។ ពាក្យសម្តីដែលសម្តែងការយកចិត្តទុកដាក់,ការកោតសរ សើរនិងអំណរគុណចំពោះសមាជិកគ្រួសារក៏ជាពន្លឺដែលផ្តល់ភាពកក់ក្តៅនិងពន្លឺដល់គេហដ្ឋានក៏ដូចជាការបួងសួងជូនពរដល់មនុស្សនៅប្រទេសឆ្ងាយៗដែលកំពុងតែជួបការលំបាកផងដែរ។ លើសពីនេះទៅទៀតមិនថាជនជាតិណា ពូជសាសន៍ណាឬសាសនាណា មនុស្សទូទាំងពិភពលោកសុទ្ធតែមានបំណងប្រាថ្នាដូចគ្នាគឺចង់ឃើញពន្លឺនៃសន្តិភាពសាយភាយទៅគ្រប់ទិសទី។

ឆ្លងកាត់តាមសង្ឃដីការបស់ព្រះស្ថាបនិកកៃសូសាម៉ាដែលចែងថា «ពន្លឺចន្លុះដែលអ្នកអុជបំភ្លឺផ្លូវដើម្បីអ្នកដទៃមួយជ្រុងនឹងមិនរលត់ឡើយ» ។សូមឱ្យយើងបន្តអនុវត្តការបង្រៀននេះកុំបីឈប់ឈរដោយមោះមុតនៅត្រង់កន្លែងដែលយើងកំពុងស្ថិតនៅនេះ។

『កូសេ』 លេខខែកញ្ញា ឆ្នាំ២០២៦






# A Global Buddhist Movement




Information about local Dharma centers

facebook

X

We welcome comments on our newsletter Living the Lotus: [living.the.lotus.rk-international@kosei-kai.or.jp](mailto:living.the.lotus.rk-international@kosei-kai.or.jp)